ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការមូលបត្រកម្ពុជា

លេខ:..............................គ.ម.ក

## លទ្ធផលកិច្ចប្រជុំ
## គណៈកម្មការមូលបត្រកម្ពុជាលើកទី ២៨

នៅរសៀលថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការមូលបត្រកម្ពុជាលើកទី ២៨។ ក្នុងកិច្ចប្រជុំគណៈកម្មការមូលបត្រកម្ពុជាលើកទី ២៨ នេះ អង្គប្រជុំបានពិនិត្យ និងពិភាក្សាលើរបៀបវារៈស្តីពី៖

១. សំណើសុំបន្តអាជ្ញាបណ្ណរបស់ក្រុមហ៊ុន អង្គរ ឃែភីថល អ៊ែតវ៉ាយហ្ស៊ែរ (Angkor Capital Advisor Co., Ltd.) និងការផ្តល់អាជ្ញាបណ្ណដល់ក្រុមហ៊ុន អេហ្វ. យូ. ជី. អាយ (F.U.G.I Gold Co., Ltd.) ធ្វើជាក្រុមហ៊ុនទីប្រឹក្សាវិនិយោគ។

២. សំណើសុំការទទួលស្គាល់ក្រុមហ៊ុនគណនេយ្យជំនាញ GRANT THORNTON (CAMBODIA); ការិយាល័យមេធាវី វ៉ាណិជ្ជ& អាសូស៊ីអ៊ែត (VINICK & ASSOCIATES) និងក្រុមហ៊ុនបោះពុម្ព អ៊ី-ព្រីនធីង (ខេមបូឌា)(E-Printing (Cambodia)) ដើម្បីផ្តល់សេវាក្នុងវិស័យមូលបត្រ។

៣. សំណើសុំការអនុញ្ញាតលើប្រតិបត្តិការគណនីអូមនីប៊ើស (Omnibus Account)។

៤. ផ្សេងៗ: រួមមានសំណើសុំកែសម្រួលសុពលភាពលេខអត្តសញ្ញាណវិនិយោគិន និងសំណើសុំពិនិត្យ សម្រេចលើសេចក្តីព្រាង “ទម្រង់ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម”។

បន្ទាប់ពីអង្គប្រជុំបានពិនិត្យ និងពិភាក្សាយ៉ាងល្អិតល្អន់ទៅលើខ្លឹមសារឯកសារវាយតម្លៃរបស់នាយកដ្ឋានជំនាញនៃ គ.ម.ក.រួចមក អង្គប្រជុំបានពិនិត្យ និងសម្រេច៖ (១).អនុញ្ញាតជាគោលការណ៍លើសំណើសុំបន្តអាជ្ញាបណ្ណរបស់ក្រុមហ៊ុន អង្គរ ឃែភីថល អ៊ែតវ៉ាយហ្ស៊ែរ (Angkor Capital Advisor Co., Ltd.) ធ្វើជាក្រុមហ៊ុនផ្តល់ប្រឹក្សាវិនិយោគក្នុងវិស័យមូលបត្រ និងអនុញ្ញាតជាគោលការណ៍ផងដែរលើសំណើសុំអាជ្ញាបណ្ណរបស់ក្រុមហ៊ុន អេហ្វ. យូ. ជី. អាយ (F.U.G.I Gold Co., Ltd.) ធ្វើជាក្រុមហ៊ុនផ្តល់ប្រឹក្សាវិនិយោគក្នុងវិស័យមូលបត្រ និងបានណែនាំឱ្យមន្ត្រីជំនាញបន្តនីតិវិធីដែលនៅសេសសល់ជាមួយក្រុមហ៊ុន។ (២).សម្រេចទទួលស្គាល់ក្រុមហ៊ុនគណនេយ្យ GRANT THORNTON ធ្វើជាក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវាក្នុងវិស័យមូលបត្រ ; សម្រេចទទួលស្គាល់ការិយាល័យមេធាវី វ៉ាណិជ្ជ&អាសូស៊ីអ៊ែត (VINICK & ASSOCIATES) ដើម្បីផ្តល់សេវាផ្នែកច្បាប់ និងសម្រេចទទួលស្គាល់ក្រុមហ៊ុនបោះពុម្ព អ៊ី-ព្រីនធីង (ខេមបូឌា) (E-Printing (Cambodia)) ជាក្រុមហ៊ុនផ្តល់សេវាបោះពុម្ពនៅក្នុងវិស័យមូលបត្រ។(៣). ចំពោះករណីសុំការអនុញ្ញាតលើប្រតិបត្តិការគណនីអូមនីប៊ើស(Omnibus Account) ក្រោយពីបានពិនិត្យ និងពិភាក្សាយ៉ាងល្អិតល្អន់ ជាពិសេសលើកត្តាហានិភ័យដែលពាក់ព័ន្ធនឹងលំហូរទុនចេញចូលដោយគំហុក អង្គប្រជុំបានសម្រេចឱ្យមន្ត្រីជំនាញធ្វើការសិក្សាស្រាវជ្រាវ និងរៀបចំជាបទប្បញ្ញត្តិក្នុងការគ្រប់គ្រងហានិភ័យដែលអាចកើតមានលើលំហូរចេញចូលដោយគំហុកនៃមូលធន តាមរយៈគណនីអូមនីប៊ើសនេះ។

នៅក្នុងរបៀបវារៈផ្សេងៗ អង្គប្រជុំក៏បានពិនិត្យ និងអនុម័តលើ (១)ប្រកាសស្តីពីការកែសម្រួលសុពលភាពលេខអត្តសញ្ញាណវិនិយោគិននៅក្នុងវិស័យមូលបត្រ ដោយបន្ថែមសុពលភាពលេខអត្តសញ្ញាណវិនិយោគិនរហូតដល់ ១០ (ដប់) ឆ្នាំ។ (២). អនុម័តលើទម្រង់ឯកសារបង្ហាញព័ត៌មានសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ នៅកម្ពុជាផងដែរ។

អង្គប្រជុំបានបញ្ចប់នៅម៉ោង ៥ និង ១៥ នាទីល្ងាច ប្រកបដោយស្មារតីទទួលខុសត្រូវ និងបានឯកភាពបន្តកិច្ចប្រជុំលើកទី ២៩ នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ ខាងមុខ។

គណៈកម្មការមូលបត្រកម្ពុជា

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា ទូរស័ព្ទ: ៨៥៥-២៣-៨៨៥-៦១១ ទូរសារ: ៨៥៥-២៣-៨៨៥-៦២២
Temporary Address: #99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
Phone : 855-23-885-611
E-mail : info@secc.gov.kh
Fax : 855-23-885-622